ទីស្តីការគណៈរដ្ឋមន្ត្រី
ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (ក.ក.ជ)

ខ្លឹមសារសង្ខេប

# ការវាយតម្លៃពាក់កណ្តាលអាណត្តិ និងជាយុទ្ធសាស្ត្រ នៃ យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភឆ្នាំ ២០១៤-២០១៨

## យុទ្ធសាស្ត្រជាតិសន្តិសុខស្បៀង និង អាហារូបត្ថម្ភ (NSFSN) ២០១៤-២០១៨

“ត្រឹមឆ្នាំ២០១៨ ប្រជាពលរដ្ឋកម្ពុជា មានលទ្ធភាពផ្នែករូបវន្ត សង្គម និងសេដ្ឋកិច្ចប្រសើរជាងមុនគួរឱ្យកត់សំគាល់ ក្នុងការទទួលបានអាហារគ្រប់គ្រាន់ មានសុវត្ថិភាព និងប្រកបដោយអាហារូបត្ថម្ភ ដើម្បីឱ្យស្របនឹងតម្រូវការផ្នែកចំណីអាហារ និងចំណង់ចំណូលចិត្ត ក្នុងការទទួលទានអាហារ ព្រមទាំងប្រើប្រាស់ស្បៀង អាហារឱ្យបានប្រសើរបំផុត ដើម្បីធ្វើឱ្យជីវិតរស់នៅរបស់ប្រជាពលរដ្ឋ មានសុខភាពល្អ និងមានផលិតភាពខ្ពស់។”

## គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី២ (SDG2)

បញ្ចប់ភាពអត់ឃ្លាន សម្រេចឱ្យបានសន្តិសុខស្បៀង និងអាហារូបត្ថម្ភប្រសើរជាងមុន និងលើកកម្ពស់កសិកម្មប្រកបដោយចីរភាព

2 ZERO HUNGER




សិក្ខាសាលាស្តីពី ការវាយតម្លៃពាក់កណ្តាលអាណត្តិ និងជាយុទ្ធសាស្ត្រ (MTSR) នៃយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភឆ្នាំ ២០១៤-២០១៨



សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីអំពី ការវាយតម្លៃពាក់កណ្តាលអាណត្តិ និងជាយុទ្ធសាស្ត្រ



សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ក្រោមជាតិស្តីអំពី ការវាយតម្លៃពាក់កណ្តាលអាណត្តិ និងជាយុទ្ធសាស្ត្រ

## វត្ថុបំណងនៃការវាយតម្លៃពាក់កណ្តាលអាណត្តិ និងជាយុទ្ធសាស្ត្រ (MTSR)

» ពិនិត្យសមិទ្ធផលនានាដែលសម្រេចកន្លងមក
» ពិនិត្យការប្រឈម និងឧបសគ្គនានា និងរកមធ្យោបាយដោះស្រាយបញ្ហា
» ពិចារណាសកម្មភាពដែលនៅពុំទាន់បានអនុវត្តមកទល់ចុងឆ្នាំ ២០១៦
» ធ្វើការវិភាគអំពីស្ថានភាពបច្ចុប្បន្ននៃវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
» រៀបចំផែនទីបង្ហាញផ្លូវមួយឆ្ពោះទៅឆ្នាំ២០៣០ និងផ្តល់មូលដ្ឋានគ្រឹះសម្រាប់ការរៀបចំយុទ្ធសាស្ត្រជាតិថ្មីសម្រាប់ ឆ្នាំ២០១៩-២០២៣
» ចងក្រង និងផ្សព្វផ្សាយលទ្ធផលឱ្យបានទូលំទូលាយលើវេទិការួមមួយ

## ដំណើរការរបស់ ការវាយតម្លៃពាក់កណ្តាលអាណត្តិ និងជាយុទ្ធសាស្ត្រ




## លទ្ធផលរបស់ ការវាយតម្លៃពាក់កណ្តាលអាណត្តិ និងជាយុទ្ធសាស្ត្រ

ការវិភាគអំពីអតីតកាល៖ ដើម្បីស្វែងយល់អំពីវឌ្ឍនភាព និងការប្រឈម
» ទំព័រទី២ » ឯកសារទី១ វឌ្ឍនភាពដែលសម្រេចបានត្រឹមឆ្នាំ ២០១៦

ការវិភាគស្ថានភាពបច្ចុប្បន្ន៖ ដើម្បីស្វែងយល់អំពីស្ថានភាពបច្ចុប្បន្ន និងនិន្នាការថ្មីៗដែលកើតមាន
» ទំព័រទី៣ » ឯកសារទី២ ស្ថានភាពបច្ចុប្បន្ន ឆ្នាំ ២០១៧

ការវិភាគអំពីទិសដៅអនាគត៖ ដើម្បីស្វែងយល់ទិសដៅយុទ្ធសាស្ត្រ និងអភិបាលកិច្ច
» ទំព័រទី៤ » ឯកសារទី៣ ទិសដៅជាយុទ្ធសាស្ត្រឆ្ពោះទៅឆ្នាំ ២០៣០

## មេរៀនទទួលបានពី ការវាយតម្លៃពាក់កណ្តាលអាណត្តិ និងជាយុទ្ធសាស្ត្រ

ការរៀបចំផែនការ និងការអនុវត្ត ដោយមានការចូលរួម៖

» អភិក្រមពិគ្រោះយោបល់ជាមួយ “សង្គមទាំងមូល” ដែលបង្កើនការចូលរួមនៅក្នុងដំណាក់កាលរៀបចំផែនការ ការអនុវត្ត និងការពិនិត្យឡើងវិញជាមួយអ្នកពាក់ព័ន្ធ។
» ការចូលរួមនៃអ្នកពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ ដែលឆ្លុះបញ្ចាំងពីការវិភាគ និងការចាត់អាទិភាពនៅថ្នាក់តំបន់។
» ដាក់មនុស្សឱ្យចំជំនាញ - ធានាថាជនបង្គោលសំខាន់ៗត្រូវបានពង្រឹងសិទ្ធិអំណាចដើម្បីចូលរួមនៅក្នុង ដំណើរការនេះទាំងមូល។
» រួមបញ្ចូលការពិគ្រោះយោបល់ឯកទេស (ជាក់លាក់តាមបញ្ហា) និងទូទៅ (ពាក់ព័ន្ធនឹងប្រធានបទទាំងអស់) ដើម្បីធ្វើឱ្យមានតុល្យភាពនិងទិដ្ឋភាពរួមនៃអាទិភាពនានា។
» ប្រមូលផ្តុំ និងចែករំលែកមូលដ្ឋានចំណេះដឹងនិងធ្វើការវិភាគបរិបទ។
» ចែករំលែកព័ត៌មាន និងផ្សព្វផ្សាយចំណេះដឹងទាក់ទងនឹងបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងយុទ្ធសាស្ត្រនានា។

## វឌ្ឍនភាព

» មានការគាំទ្រដ៏រឹងមាំ និងកម្រិតខ្ពស់ ទៅលើវិធីសាស្ត្រទូលំទូលាយក្នុងការដោះស្រាយបញ្ហាសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ។

» វឌ្ឍនភាពបានកើតមានឡើងនៅគ្រប់ផ្នែកទាំងអស់។ សកម្មភាពអាទិភាពទាំងអស់កំពុងត្រូវបានអនុវត្ត ប៉ុន្តែការអនុវត្តពុំទាន់បានគ្របដណ្តប់ស្មើភាព និងនៅមានការវាស់វែងវឌ្ឍនភាពតិចតួច សម្រាប់ឆ្ពោះទៅរកគោលដៅជាតិ។

» របាយការណ៍វឌ្ឍភាពបង្ហាញពីភាពរីកចំរើនខ្លាំងជាងគេលើផលិតកម្មកសិកម្ម កម្មវិធីសុខាភិបាល និងទឹកស្អាត។

» ការមានស្បៀងអាហារ៖ មានវឌ្ឍនភាពល្អទៅលើផលិតកម្មកសិកម្ម ប៉ុន្តែខ្វះភាពចម្រុះនៃអាហារ។

» ការអនុវត្តសកម្មភាពទឹកស្អាត និងអនាម័យមានដំណើរការល្អ៖ ការអនុវត្តអនាម័យមូលដ្ឋានសម្រេចបានលើសពីគោលដៅឆ្នាំ ២០១៨ ចំណែកអនាម័យទូទៅ សម្រេចបានលើសពីគោលដៅឆ្នាំ ២០១៦។

## ការប្រឈម

» លទ្ធភាពនៃការទទួលបាន និងការបឺតស្រូបស្បៀងគឺជាការប្រឈមដែលកំពុងកើតមាន។ ភាពមានស្បៀង និងផលិតកម្មគឺជាចំនុចផ្តោតសំខាន់ក្នុងពេលបច្ចុប្បន្ន។

» ស្ថិរភាព៖ គ្រោះមហន្តរាយ និងវិបត្តកើតមានឡើងម្តងម្កាល ដែលបង្កឱ្យប្រជាពលរដ្ឋដែលខ្វះសន្តិសុខស្បៀង និងងាយរងគ្រោះទទួលរងនូវហានិភ័យច្រើនជាងគេ (ឧទាហរណ៍ គ្រោះរាំងស្ងួតឆ្នាំ ២០១៦) ។

» ការអនុវត្ត និងការផ្តល់មូលនិធិក្នុងស្រុកមានដែនកំនត់ លើកលែងតែវិស័យសុខភាព - ការប្រឈមក្នុងការផ្តល់ហិរញ្ញវត្ថុសម្រាប់ការអនុវត្តកម្មវិធី។

» ត្រូវការតភ្ជាប់ និងពង្រឹងកិច្ចសន្ទនា និងកិច្ចគាំទ្រដល់ថ្នាក់ក្រោមជាតិ។

» យុទ្ធសាស្ត្រជាតិសន្តិសុខស្បៀង និង អាហារូបត្ថម្ភគួរចាំបាច់ផ្តោតលើសកម្មភាព 'អាទិភាព' ជាជាងលទ្ធផល។

» ចាំបាច់ត្រូវមានការកសាងសមត្ថភាពនៅគ្រប់កម្រិត។




ការបង្កើនអាហារូបត្ថម្ភ - វឌ្ឍនភាពស្ថាប័ននៅកម្ពុជា ឆ្នាំ២០១៥-២០១៧ (SUN, ២០១៥, ២០១៦, ២០១៧)*




ផលិតកម្មដំណាំឧស្សាហកម្ម (NIS, 2014)*

ខណៈពេលដែលផលិតកម្មស្រូវបានកើនឡើងយ៉ាងច្រើន គេឃើញថាភាពចម្រុះនៃដំណាំនៅមានដែនកំណត់។ ក្រៅពីនេះ របៀបនៃការទទួលទានរបស់ប្រជាជនកម្ពុជាក៏ស្តែងឱ្យឃើញផងដែរថា អង្ករ/បាយគឺជាផ្នែកមួយដ៏សំខាន់បំផុតនៅក្នុងរបបអាហារ។

ថ្វីបើអត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយក្តី ប្រជាពលរដ្ឋកម្ពុជាមួយភាគធំបានរួចផុតពីខ្សែបន្ទាត់នៃភាពក្រីក្រក្នុងកម្រិតទាបនៅឡើយ ដែលភាគច្រើននឹងងាយរងគ្រោះនៅពេលមានវិបត្តិ (World Bank, 2013)*។




ផលប៉ះពាល់នៃបាតុភូត អែលនីញ៉ូ ទៅលើហិរញ្ញវត្ថុរបស់គ្រួសារ (FAO et al., 2016)*

* សម្រាប់ប្រភពឯកសារពេញលេញ សូមមើលនៅក្នុងឯកសារទី២ ស្ថានភាពបច្ចុប្បន្ន ឆ្នាំ ២០១៧

## ស្ថានភាព

» មានការរីកចម្រើនគួរអោយចាប់អារម្មណ៍នៅក្នុងកំណើនជាតិ និងវឌ្ឍនភាពលើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។
» ប៉ុន្តែ នៅមានវិសមភាពកំណើន និងស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅទូទាំងប្រទេស និងសម្រាប់ក្រុមប្រជាពលរដ្ឋដែលនៅតាមទីតាំងភូមិសាស្ត្រផ្សេងៗ និងមានកម្រិតសេដ្ឋកិច្ចសង្គមផ្សេងៗ។
» មានការយឺតយ៉ាវទៅលើសូចនាករអភិវឌ្ឍន៍ធនធានមនុស្សមួយចំនួន - ចាំបាច់ត្រូវការផ្តល់អាទិភាពដល់លទ្ធភាពក្នុងការទទួលបានអាហារសម្បូរជីវជាតិ និងសេវាសង្គម។
» មានហានិភ័យក្នុងករណីមានវិបត្តិ។

## និន្នាការថ្មីៗ ដែលកើតមានឡើង

» ដើម្បីជំរុញកំណើនសេដ្ឋកិច្ចចាំបាច់ត្រូវមានការវិនិយោគទៅលើធនធានមនុស្ស រួមទាំងការផ្តោតជាពិសេសលើអាហារូបត្ថម្ភ ដើម្បីរក្សាឱ្យបាននូវផលិតភាព និងលទ្ធភាពក្នុងការប្រកួតប្រជែង។
» ចំណាកស្រុក ជាពិសេសទៅកាន់ទីក្រុង គឺជាចំនុចចាំបាច់ដែលត្រូវពិចារណា។
  » ប្រជាពលរដ្ឋក្រីក្រនៅតាមទីក្រុង មានការលំបាកក្នុងការទទួលបានសេវាទឹកស្អាត អនាម័យ និងសុខភាព។
  » បម្លាស់ប្តូរទៅលំនៅទៅកាន់ទីក្រុង បង្កនូវផលប៉ះពាល់មួយចំនួនចំពោះអាហារូបត្ថម្ភរបស់កុមារ ដោយអត្រានៃការបំបៅដោះកូននៅរាជធានីភ្នំពេញមានកម្រិតទាបជាងគេបំផុត។
» កម្ពុជាមានការផ្លាស់ប្តូររបបអាហារ ឆ្ពោះទៅរកការបរិភោគអាហារស្រាប់ងាយៗ ដែលនេះគឺជានិន្នាការឆ្ពោះទៅរកភាពធាត់ និងហានិភ័យនៃជម្ងឺមិនឆ្លង។
» កម្រិតនៃការប្រែប្រួលអាកាសធាតុក្នុងរយៈពេល40ឆ្នាំកន្លងមកមានល្បឿនលឿនជាងលទ្ធភាពនៃការបន្សាំបច្ចេកទេសកសិកម្មក្នុងស្រុក។ ហានិភ័យដោយសារគ្រោះមហន្តរាយធម្មជាតិនឹងមានកម្រិតកាន់តែធ្ងន់ធ្ងរឡើងដោយសារមានការខូចខាតទៅលើបរិស្ថានជាបន្តបន្ទាប់។




ចំណែកនៃប្រាក់ចំណូលប្រចាំគ្រួសារ ទៅតាមចំណែកបញ្ចភាគ (WFP, 2016)*




ភាគរយនៃចំណាកស្រុកតាមទិសដៅ (WFP, 2017f)*




ថ្វីបើមាននិន្នាការវិជ្ជមានក៏ដោយ បញ្ហាអាហារូបត្ថម្ភនៅតែបន្តបង្កជាបញ្ហាដែលមិនអាចស្តារបាន ដល់ការអភិវឌ្ឍរបស់កុមារ ដែលរួមចំណែកបង្កឱ្យមានផលិតភាពការងារទាប និងចំណូលទាបនៅពេលពួកគេពេញវ័យ (NIS et al., 2001, 2006, 2011, 2015) * ។




គេសង្កេតឃើញថា កម្ពុជាមានការផ្លាស់ប្តូររបបអាហារឆ្ពោះទៅរកការបរិភោគអាហារស្រាប់ងាយៗ ដែលនេះគឺជានិន្នាការឆ្ពោះទៅរកភាពធាត់ និងហានិភ័យនៃជម្ងឺមិនឆ្លង (MoH, 2013)*។

# ការសម្រេចគោលដៅ SDG2 – ទិសដៅយុទ្ធសាស្ត្រ




| | |
|---|---|
| ផ្តោតលើអាហារដែលមានគុណភាព ចម្រុះ ធន់នឹងអាកាសធាតុ និងកសិកម្មដែលគិតគូរពីអាហារូបត្ថម្ភ | ធ្វើពិពិធកម្មផលិតកម្មកសិកម្ម។ កែលម្អសង្វាក់តម្លៃផលិតកម្ម។ បង្កើនគុណភាព និងសុវត្ថិភាពម្ហូបអាហារ។ លើកកម្ពស់បច្ចេកទេសកសិកម្មដែលមានប្រសិទ្ធភាព។ បង្កើនភាពមានស្បៀង ស្ថិរភាពស្បៀង និងប្រសិទ្ធភាព។ ពិនិត្យឡើងវិញអំពីការផ្តោតលើការនាំចេញ។ |
| បង្កើនសមធម៌ក្នុងការទទួលបានស្បៀង (មិនទុកឱ្យនរណាម្នាក់នៅក្រោយការអភិវឌ្ឍ) | បង្កើនលទ្ធភាពក្នុងការទទួលបានស្បៀង។ ដោះស្រាយវិសមភាពក្នុងការទទួលបានស្បៀង។ ពិនិត្យយុទ្ធសាស្ត្រអន្តរាគមន៍។ លើកកម្ពស់ការយល់ដឹងអំពីជម្រើសចំណីអាហារ - របបអាហារចម្រុះ។ ពង្រឹងប្រព័ន្ធសុវត្ថិភាពសង្គម។ |
| ចាត់អាហារូបត្ថម្ភជាអាទិភាព និងដោះស្រាយការប្រឈមដែលកើតមានឡើងថ្មីៗ | បង្កើនសេវាទឹកស្អាតនិងអនាម័យ។ កែលម្អរបៀបផ្តល់អាហារដល់ទារកនិងមាតា។ អាហារូបត្ថម្ភសម្រាប់កុមារ និងក្មេងជំទង់។ ចាត់ទុក អាហារូបត្ថម្ភជាការវិនិយោគធនធានមនុស្ស។ ដោះស្រាយបន្ទុកទ្វេដងនៃបញ្ហាអាហារូបត្ថម្ភ និងកំណើននៃជំងឺមិនឆ្លង។ កែលម្អយុទ្ធសាស្ត្រ ក្នុងការប្រាស្រ័យទាក់ទង។ |
| បន្តធានាភាពមាន ការទទួលបាន និងការបឹតស្រូបស្បៀង ក្នុងករណីមានវិបត្តិ តាមរយៈវិធានការកាត់បន្ថយហានិភ័យ និងកិច្ចគាំពារសង្គម | កែលម្អប្រព័ន្ធគាំពារសង្គម ដើម្បីឆ្លើយតបឱ្យបានប្រសើរទៅនឹងវិបត្តិ។ បង្កើនភាពស៊ាំ នឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ រួមទាំងការការពារបរិស្ថាន។ បន្តពង្រឹងលើយន្តការគ្រប់គ្រងវិបត្តិដែលអាចកើតមាន (ដូចជា វិបត្តិអាកាសធាតុ សេដ្ឋកិច្ច សុខភាព ជាដើម)។ បង្កើនភាពធន់របស់សហគមន៍ចំពោះវិបត្តិ។ |

## មិនទុកឱ្យនរណាម្នាក់នៅក្រោយការអភិវឌ្ឍ

» រៀបចំយុទ្ធសាស្ត្រផ្សេងៗ ដែលសមស្របទៅតាមទីតាំងភូមិសាស្ត្រ ឬប្រជាសាស្ត្រ សេដ្ឋកិច្ចសង្គម និងក្រុមជនជាតិភាគតិច។ល។

» ពិចារណាអំពីប្រេវ៉ាឡង់បន្ទុក/តម្រូវការ និងភាពងាយរងគ្រោះ

## អាហារូបត្ថម្ភ ជាចលករក្នុងការពន្លឿន SDGs

អាហារូបត្ថម្ភអាចត្រូវបានចាត់ទុកជាចលករពន្លឿន និងគួរត្រូវបានផ្តល់នូវអាទិភាពខ្ពស់ជាងគេ ដើម្បីឱ្យវាអាចរួមចំណែកជាវិជ្ជមានទៅដល់SDGs ដទៃទៀត។

# ការពិចារណាជាគន្លឹះ សម្រាប់អភិបាលកិច្ច

## យុទ្ធសាស្ត្រ

» បង្ហាញចក្ខុវិស័យFSN 2030: CSDGs និងNSDP 2019-2023

» រៀបចំជំហរជាយុទ្ធសាស្ត្រសម្រាប់ NSFSN

» ពិនិត្យឡើងវិញ និងកែសម្រួលក្របខ័ណ្ឌ FSN

» ពង្រឹងសមត្ថភាព និងគោលនយោបាយតាមវិស័យដែលមានស្រាប់

» ពិចារណាអំពីចំនុចផ្តោត និងចំនុចអាទិភាព

## ការសម្របសម្រួល

» កំណត់ឱ្យច្បាស់នូវ តួនាទី និងការទទួលខុសត្រូវរបស់ក.ក.ជ.

» រៀបចំអាទិភាព និងផែនការសកម្មភាពរួម

» កិច្ចសហការពហុវិស័យ និងការងារតាមវិស័យ

» ថវិកានិងប្រភពធនធាន - បង្កើនធនធានហិរញ្ញវត្ថុក្នុងស្រុក

» គណនេយ្យភាព

## ការចូលរួម

» លើកកម្ពស់សិទ្ធិអំណាច និងការចូលរួមរបស់ថ្នាក់ក្រោមជាតិ

» ប្រមូលផ្តុំសង្គមស៊ីវិលដើម្បីសកម្មភាពសហគមន៍

» លើកកម្ពស់ការចូលរួម និងកសាងសមត្ថភាពអ្នករៀបចំគោលនយោបាយ និងអ្នកគ្រប់គ្រង។

» លើកកម្ពស់ការចូលរួមពីវិស័យឯកជន ស្ថាប័នអប់រំ និងប្រព័ន្ធផ្សព្វផ្សាយ

## ព័ត៌មាន

» ការគ្រប់គ្រងព័ត៌មាន (ការស្រាវជ្រាវ ការចែករំលែក ការប្រើបច្ចេកវិទ្យា និងប្រព័ន្ធ M&E)

» យុទ្ធសាស្ត្រប្រាស្រ័យទាក់ទងរួមសម្រាប់ FSN

» ការលើកកម្ពស់ការយល់ដឹង និងការតស៊ូមតិ

» គណនេយ្យភាព និងយន្តការរាយការណ៍

» រៀបចំ និងបង្កើតឱ្យមាននូវសូចនាករ និងប្រភពរបស់វា

# អាទិភាពសម្រាប់ឆ្នាំ២០១៨

» កែលម្អផែនទីបង្ហាញផ្លូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ឆ្នាំ ២០៣០ ដោយផ្អែកលើ SDGs របស់កម្ពុជា និងសកម្មភាពដែលមានស្រាប់ ព្រមទាំងសូចនាករនៅក្នុង សូចនាករសម្រាប់តាមដានរួមគ្នា(JMIs) និងNSFSN ដើម្បីធ្វើសនិទានកម្មសូចនាករ ចំណុចដៅ និងប្រព័ន្ធព័ត៌មាន។

» កំណត់ប្រភពហិរញ្ញវត្ថុ ដែលអាចយកមកប្រើប្រាស់ទៅអនាគត ដើម្បីអនុវត្តវិស័យដែលពុំទទួលបានមូលនិធិគ្រប់គ្រាន់។ ករណីនេះទាមទារឱ្យមានការប្រាស្រ័យទាក់ទងស្អិតរមួតជាបន្តបន្ទាប់ អំពីសារៈសំខាន់នៃFSNដែលជាគន្លឹះក្នុងការអភិវឌ្ឍ និងការតស៊ូមតិជាមួយអ្នកធ្វើសេចក្តីសម្រេចចិត្ត។

» ធ្វើការវិភាគស្ថាប័ននិងសមត្ថភាពសម្រាប់របៀបវារៈវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភឆ្នាំ ២០៣០ ដើម្បីបញ្ជាក់ពីគណនេយ្យភាព ឆ្ពោះទៅរកការអនុវត្តយុទ្ធសាស្ត្រនានាទៅថ្ងៃអនាគត។

» ពិនិត្យឡើងវិញនូវគោលបំណងនៃយុទ្ធសាស្ត្រជាតិស្តីពីFSN និងភាពបន្ស៊ីគ្នាជាមួយក្របខ័ណ្ឌ គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការនានា ដោយប្រើប្រាស់ការរៀនសូត្រដែលទទួលបានពីការវាយតម្លៃពាក់កណ្តាលអាណត្តិ និងជាយុទ្ធសាស្ត្រនេះ។

» បន្តស្រាវជ្រាវ និងវិភាគ ដើម្បីកែលម្អការតាមដានភាពងាយរងគ្រោះ និងការឆ្លើយតប និងបង្កើតជាយុទ្ធសាស្ត្ររឹងមាំមួយដែល “មិនទុកឱ្យនរណាម្នាក់នៅក្រោយការអភិវឌ្ឍ”។